# យើងគ្រាន់តែសុំមហាក្សត្រ អនុវត្តមាត្រាទី៨នៃរដ្ឋធម្មនុញ្ញ ប៉ុណ្ណោះ !

## តើវាធ្ងន់ធ្ងរខ្លាំងក្លាណាស់ទៅឬ ?

ដោយលី-ឌៀប ★ ថ្ងៃទី២០ មីនា ២០០៥

ប៉ុន្មានថ្ងៃកន្លងមកនេះ លោកសីហនុហាក់ដូចជាខ្វល់ខ្វាយនឹងរឿងបាត់បង់ទឹកដីព្រះនគរសំបើមណាស់ ។ ទំនងមើលទៅ ដូចជាគាត់លេបគាត់លេបថ្នាំខុសទេដឹង បានជាចេញក្រឡាសារយ៉ាងដូច្នេះ ?

បញ្ហាទាំងពីរនេះ កើតមានតាំងពីជំនាន់អុងល្ងង់ណាស់មកហើយ ។ ខ្មែរយើងបាត់បង់ទឹកដីកម្ពុជាក្រោម «ជាផ្លូវការ» កាលជំនាន់គាត់សោយរាជ្យលើកទី១ គឺនៅឆ្នាំ១៩៤៩មកម្ល៉េះ ។ ហើយបញ្ហាព្រំប្រទល់ដែនខ្មែរបច្ចុប្បន្នជាមួយយួនទៀតសោត ក៏ស្ថិតនៅក្រោមរាជ្យនិងក្រោមការទទួលខុសត្រូវរបស់គាត់ដដែល (ទសវត្សឆ្នាំ៦០) ដែលជាមូលហេតុដ៏ចំបងមួយ ជម្រុញឲ្យកើតមានព្រឹត្តិការណ៍១៨មិនា១៩៧០ ។

នៅក្នុងអត្ថបទទាំងពីរទាំងបីរបស់គាត់ ចុះផ្សាយក្នុង <ព្រឹត្តិប័ត្រឯកសារប្រចាំខែ BMD ថ្ងៃទី១៦-១៧-១៨មីនា២០០៥>, លោកសីហនុធ្វើមើលតែរាស្ត្រខ្មែរគ្មានដឹងអ្វី និងពុំបានឮពីការហោកហាកគ្មានបានការរបស់គាត់រាប់ឆ្នាំមកហើយយ៉ាងដូច្នោះ (!!)

បំភ្លេចទៅចុះ ! ក្នុងការទាមទារទឹកដីកម្ពុជាក្រោមពីយួនមកវិញ ពីព្រោះទោះបីយ៉ាងណាក៏ដោយ ក៏គាត់ជ្រុលជាចូល <រ៉ុត្រែត> ហួសទៅហើយ ៗកិច្ចការអស់ទាំងនេះ វាបានធ្លាក់ទៅជាកាតព្វកិច្ចរបស់បងប្អូនខ្មែរកម្ពុជាក្រោម ដែលត្រូវធ្វើតស៊ូទាមទារទឹកដីដូនតានោះ មកជារបស់ភិនខ្មែរយើងឡើងវិញ ដោយខ្លួនឯងទៅហើយ ។

បងប្អូនរបស់យើង លោកអស់សេចក្តីសង្ឃឹមរលីងធេងពីសីហនុ ! បើសីហនុគាត់ពិតជាស្រឡាញ់ទឹកដីត្រង់ម្តុំនោះមែន នោះគាត់មុខជាមិនធ្វើឲ្យរបូតទៅព្រះចៅបាវដាយកាលពីជាងកន្លះសតវត្សមុននោះទេ ។ គាត់សុខចិត្តបាត់បង់<កម្ពុជាក្រោម>ទាំងមូល ដើម្បីប្តូរគ្នាទៅនឹងព្រះរាជបល្ល័ង្ក ព្រមទាំងឯករាជភាពបរិបូណ៌កាលពីឆ្នាំ១៩៥៣ ។ មានន័យថា លោកសីហនុខាតដីមួយចំហៀងនគរ ដើម្បីឲ្យខ្លួនបានសោយរាជ្យ និងបានឯករាជ្យ ដោយពុំចាំបាច់ធ្វើការតស៊ូអ្វីធំដុំឡើយ គឺគ្រាន់តែប្រើកងជីវពលនារីក្លាហានលីកាំភ្លើងឈើនិងបំពង់ឫស្សីបង្អួតបារាំងបានហើយ ។

ដប់ឆ្នាំក្រោយពីការបាត់បង់ទឹកដីកម្ពុជាក្រោម លោកសីហនុក៏ធ្វើកំហុសមួយទៀត គឺបានទៅចាញ់បោកយួនយៀកកុង-យៀកណាមខាងជើង ដោយអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីខ្មែរនៅតាមបណ្តោយព្រំដែនខាងកើត ធ្វើជាមូលដ្ឋានទ័ពរបស់ពួកគេដើម្បីច្បាំងជាមួយកងទ័ពអាមេរិកាំងនិងសម្ព័ន្ធមិត្តយៀកណាមខាងត្បូង ។

នៅរាល់សំបុត្រឆ្លងឆ្លើយ អនុស្សាវរណៈ និងកិច្ចសន្យានានា យើងតែងសង្កេតឃើញពុំមានខាកខានក្នុងការប្រើពាក្យ «គោរពឯករាជភាព អធិបតេយ្យភាព និងបូរណភាពទឹកដី» គ្នាទៅវិញទៅមកសោះ ។ ពាក្យអស់នេះ វាស្មើរទៅជាមេសូត្រចាំរត់មាត់រ៉ិលទៅហើយ ។ តែនៅទីបំផុត គឺពួកកងទ័ពយួនយៀកកុង-យៀកណាមខាងជើងនេះឯងហើយ ដែលត្រូវសីហនុពន្យុះឲ្យចូលវាយប្រហារដល់បេះដូងរបស់ជាតិតែម្តង ។ សីហនុមិនហៅប្រតិបត្តិការយោធានោះថា ជា<អំពើឈ្លានពានកម្ពុជា>ទេ ពីព្រោះវាជាទ័ពដែលសីហនុគាត់ខ្ចីប្រើ ដើម្បីឲ្យចូលទៅដណ្តើមយកអំណាចមកប្រគល់ឲ្យខ្លួនគាត់ជាថ្មី ។

ចំណែកកងទ័ពសាធារណរដ្ឋខ្មែរ ដែលបានបូជាជីវិតដើម្បីការពារទឹកដីខ្មែរ ប្រែត្រឡប់ជាត្រូវសីហនុរិះគន់ថា ជាកងទ័ពនៃបនពួកក្បត់ និងជាបាវបំរើចក្រពត្តិប្រតិកិរិយាអាមេរិកាំងទៅវិញ សូម្បីតែរហូតមកដល់ពេលនេះសហរដ្ឋអាមេរិកពុំដែលបានកាន់កាប់ស្រុកខ្មែរដល់ម្តងណាសោះក៏ដោយ (គ្មានមូលដ្ឋានទ័ពទីងរបស់អាមេរិកាំងស្ថិតនៅក្នុងស្រុកខ្មែរ ដូចនៅយួនខាងត្បូង និងនៅស្រុកថៃទេ) ។

កំហុសដ៏មហាធ្ងន់ធរមួយទៀតរបស់សីហនុ គឺគាត់បានធ្វើជាមេដឹកនាំបនពេជ្ឈឃាតខ្មែរក្រហម ប្រព្រឹត្ត«អំពើសម្លាប់រង្គាល»ទៅលើប្រជាពលរដ្ឋខ្មែរអស់៣លាននាក់ នៅចន្លោះចាប់ពីឆ្នាំ១៩៧៥ទៅដល់ឆ្នាំ១៩៧៩ មុនពេលគាត់ហាក់ទៅចូលដៃជាមួយពួកអាយ៉ងយួន ក្នុងអំឡុងកន្លងមួយទសវត្ស ក្រោយពីអំពើឈ្លានពាននៃកងទ័ពយួន ដែលគាត់ធ្លាប់ពឹងពាក់កាលទសវត្ស៧០ ចូលឈ្លានពានស្រុកខ្មែរពេញទសវត្ស៨០ ។

សុំសួរថា តើបញ្ហាព្រំដែនខ្មែរនឹងត្រូវបានដោះស្រាយចេញឬទេនៅក្រោមសម័យរាជាណាចក្រទី២ ? ។ ចម្លើយ គឺអត់ផ្លូវដដែល ! ។ កត្តាដែលគ្មានច្រកចេញ គឺមកពីពួកមេៗខ្មែរដែលនៅក្នុងនោះមានរួមទាំងសីហនុផង បានត្រូវយួនដកហូតព្រលឹងព្រលះអស់ទៅហើយ ។ កុំនិយាយដល់ធ្វើការតវ៉ាទាមទារ សូម្បីតែលើកយកបញ្ហានេះមកនិយាយគ្នាឯងសោះ ក៏មិនហ៊ានទាំងនិយាយផង ។

យូរៗម្តង យើងតែងឮសួរសីហនុបូលក្លេវៗ របៀបហោកហាក ដើម្បីឲ្យឆ្លងទៅផុតពីមុខពីមាត់គាត់ នៅពេលណាមានការស្រែកមិនសប្បាយចិត្តពីសំណាក់បងប្អូនប្រជាពលរដ្ឋខ្មែរម្តងៗ ។

<គណៈកម្មាធិការព្រំដែនកម្ពុជា> ដែលមានទីស្នាក់ការនៅស្រុកបារាំង និងមានលោកស៊ាន-ប៉េងសែជាប្រធាន បានខិតខំធ្វើការអំពាវនាវហើយអំពាវនាវទៀត សុំឲ្យតែព្រះមហាក្សត្រនិងរាជរដ្ឋាភិបាលប្រកាសលុបសន្ធិសញ្ញាខ្មែរ-យួនចោល ដែល<អតីតរដ្ឋកម្ពុជា>បានធ្វើកាលពីឆ្នាំ១៩៧៩-៨០-៨២-៨៣ និង៨៥ ដោយអនុលោមតាមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ។ តែគ្មានឃើញស្តេចនិងមន្ត្រីខ្មែរណាធ្វើទេ (!!)

និយាយថា ហ៊ុន-សែនមិនធ្វើទៅចុះ ពីព្រោះមកពីជា «អាយ៉ងយួន»... ចុះសីហនុដែលមិនព្រមធ្វើដែរនោះ តើគាត់ជា «អាយ៉ង» អ្នកណាដែរទៅ ? ឬមួយជាប់ក្អែល<កញ្ជះយួន>តាំងពីអំឡុងឆ្នាំ៦០មក ? ។ រឿងសំខាន់មួយដែលយើងចងចាំ គឺនៅក្រោយពេលសីហនុវិលត្រឡប់ចូលទៅស្រុកខ្មែរវិញ (ថ្ងៃទី១៤វិច្ឆិកា១៩៩១) ថ្ងៃទី២៥កុម្ភៈ១៩៩២ សីហនុបានប្រកាសឲ្យពិភពលោកបានឮខ្ទរខ្ទារថា ៖ គាត់រកមិនឃើញមានទាហានយួនមួយគ្រាប់ណាសោះនៅក្នុងស្រុកខ្មែរ ។ ពុទ្ធោ (!!)

សីហនុមិនធ្វើតាំងពីពេលនៅសោយរាជ្យ រហូតចូលរ៉ុត្រែត ហើយផ្ទេររាជ្យទៅឲ្យកូន ក៏ស្តេចកូននៅតែមិនធ្វើដូចគ្នា ។ បើទាំងស្តេចឪស្តេចកូនមិនធ្វើនូវទង្វើយ៉ាងស្របច្បាប់មួយ (តាមមាត្រាទី៨នៃរដ្ឋធម្មនុញ្ញ) យ៉ាងដូច្នេះទៅហើយ តើចង់<ស៊ីជោរ>និយាយអំពីរឿងអ្វីដែរទៅ (??)

ខាងក្រោមនេះ ជាការបកប្រែក្រៅផ្លូវការ នូវអត្ថបទរបស់សីហនុដែលគាត់សរសេរចុះនៅក្នុង<ព្រឹត្តិប័ត្រឯកសារប្រចាំខែ -BMD>របស់គាត់ ៖

«ព្រឹត្តិប័ត្រឯកសារប្រចាំខែ

«នរោត្តម-សីហនុ

«ប៉េកាំង, ថ្ងៃទី១៦ មីនា ២០០៥

«ថ្ងៃនេះ, គ្មាននរណាម្នាក់អាចបដិសេធការពិតដែលថា កម្ពុជានៃរាជាណាចក្រទី២ បានបាត់បង់មួយផ្នែកនៃបូរណភាពដែនដីគោកនិងសមុទ្រដែលខ្លួនមានការពីអំឡុងឆ្នាំ១៩៦៣ (ជាមួយនិងការវិលត្រឡប់នៃប្រាសាទព្រះវិហារ) នៅឆ្នាំ១៩៦៩នោះទេ ។

ថ្ងៃនេះ, គេបានដឹងយ៉ាងច្បាស់ថា ដែនដីនិងដែនសមុទ្ររបស់យើងមួយផ្នែកធំ កាលពីជំនាន់ឆ្នាំ១៩៦៣-១៩៦៩ កាន់តែរួមចូលមក ដោយគ្មានការតវ៉ាប្រឆាំងអ្វីទាំងអស់ ចំពោះដែលគេហៅថា«អធិបតេយ្យភាព» ពីអ្នកជិតខាងទាំងបីរបស់យើង (មានថៃ, វៀតណាម និងលាវ) ដែលម្នាក់ៗបានបេះបោចមួយចំណែកថ្មីថែមទៀតនៃនំរបស់ខ្មែរ ។

ជាឧទាហរណ៍, យើងបានរកឃើញភូមិមួយចំនួនរបស់ប្រជារាស្ត្រយើង ដែលស្ថិតនៅខាងក្នុងកម្ពុជានៃសង្គមរាស្ត្រនិយម ហើយឥឡូវនេះប្រែជាពជិង «ពុទ្ធោអើយ» នៅខាងក្នុងទឹកដីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (វៀតណាមខាងត្បូង) ទៅវិញ... ដែលការពារដោយកងទ័ព (ដ៏មិនចេះចាញ់នរណា) នៃ«បងវៀតណាម»របស់យើង ។

ពេលថ្មីៗនេះ, លោកគ្រូ Michel Buisson និងមិត្តភក្តិបានគូសបញ្ជាក់ឲ្យដឹងថា «បងយៀកណាម»នេះ បានក្លាយទៅជាម្ចាស់ភូមិខ្មែរអស់នោះទៅហើយ ពីព្រោះមកពីបងប្អូនរួមជាតិរបស់យើងក្រខ្លាំងពេកត្រូវជួលដីទៅឲ្យគេ ឬហើយដែលធ្ងន់ធ្ងរជាងនេះទៅទៀតនោះ គាត់លក់ទៅឲ្យ«បងយៀកណាម»តែម្តង ។ លោកគ្រូ Buisson (បារាំង) បានឃើញនឹងភ្នែក ថាពួកយៀកណាមរុញ«ព្រំដែនថ្មី»ពីវៀតណាមខាងត្បូងចូលមកខាងក្នុងទឹកដីខ្មែរនៃ«រាជាណាចក្រទី២» ។

q

គឺជាការពិតហើយដែលថា នៅក្រោមការគ្រប់គ្រងរបស់លន់-នល់ (នៃសាធារណរដ្ឋខ្មែរ) ពួកជនជាតិវៀតណាមពី«វៀតណាមខាងត្បូង» (កម្ពុជាក្រោម) បានផ្ញើសំបុត្រមកជនជាតិយៀកណាមនៅស្វាយរៀង ដោយសរសេរយ៉ាងច្បាស់នៅលើស្រោមសំបុត្រថា «ស្វាយរៀង, ប្រទេសយៀកណាម» (sic!) ។

( កកន ៖ សីហនុកំពុងធ្វើជាភ្លេចថា នៅពេលនោះ គឺខ្លួនគាត់នេះហើយដែលជាអ្នកទៅគៀងគរនិងពន្យុះកងទ័ពយួន ឲ្យហក់ចូលមកឈ្លានពានស្រុកខ្មែរ ផ្តិលផ្តាច់អាយុជីវិតប្រជារាស្ត្រខ្លួនឯង និងប្លន់ទ្រព្យសម្បត្តិខ្មែរសឹងពាយអស់មួយនគរ ។ គិតទៅ... គាត់នៅមានមុខក្រាស់ចង់ដាក់កំហុសទៅលើលោកលន់-នល់ ដែលជាអ្នកខំការពារទឹកដីខ្មែរនោះសោះទៅវិញ ? ) ។

វាជាការពិតផងដែរដែលថា កងទ័ពរបស់ង្វៀង-វ៉ាន់ធីវ បានកាន់កាប់ក្រុងអ្នកលឿងរបស់យើង រួចដូរឈ្មោះថាជា «សៃហ្គុងមើយ» (ប្រែថាក្រុងសៃហ្គុងថ្មី ឬជាភាសាបារាំងហៅថា NOUVEAU SAIGON ) ។

q

វិលត្រឡប់ទៅលោកគ្រូ Michel Buisson វិញ, គាត់បានឃើញទាហានវៀតណាមតាំងខ្លួនធ្វើជាមេកើយលើប្រជារាស្ត្រខ្មែរក្នុងភូមិខ្មែរនៅស្រុកស្នួល ។

q

សាធារណរដ្ឋសង្គមនិយមវៀតណាម «បានបង្កើត»ព្រំដែនថ្មី (ជាប្រយោជន៍ខាងគេ) ដោយសង់ក្នុងអំឡុងទសវត្សឆ្នាំ៨០, ៩០ និង២០០០ នូវ «ច្រកទ្វារចូល» ព្រមទាំងជីកព្រែកនៅក្នុងរង្វង់ព្រំដែនទឹកដីរបស់យើងឆ្នាំ១៩៦៣-១៩៦៩ ។

ថៃ, ខាងផ្នែករបស់គេ ក៏បាន«បង្កើត»ព្រំដែនថ្មី (ជាប្រយោជន៍របស់គេ) ដោយសាងសង់ផ្លូវធំពុះកាត់ខេត្តខ្មែរខ្លះនៃ«រាជាណាចក្រទី២» ។ ដីទាំងនោះ គឺស្ថិតនៅជិតស្រុកថៃតាមបណ្តោយផ្លូវធំនៅខាងលើ ដែលចាប់ពីឥឡូវនេះទៅ ក្លាយជារបស់រាជាណាចក្រថៃ ។

q

ថ្ងៃនេះ ទង្វើដែលក្រុមរបស់ឯ.ឧ. វ៉ា-គឹមហុង កំពុងធ្វើការជាផ្លូវការជាមួយប្រទេសជិតខាងយើងទាំងបី ដើម្បីរកឲ្យដឹងថា តើព្រំដែនខ្មែរមានភស្តុតាងច្បាស់ពិតប្រាកដនៅត្រង់កន្លែងណា ៖

ទីមួយ, សាធារណរដ្ឋសង្គមនិយមវៀតណាម, រាជាណាចក្រថៃ និងសាធារណរដ្ឋប្រជាមានិតលាវ មិនទទួលស្គាល់ជាដាច់ខាត នូវភាពត្រឹមត្រូវនិងស្របច្បាប់នៃព្រំដែនខ្មែរ ក្នុងអំឡុងឆ្នាំ១៩៦៣ ទៅឆ្នាំ១៩៦៩ (ទោះបីនៅពេលប្រជុំកំពូលប្រជារាស្ត្រឥណ្ឌូចិននៅទីក្រុងកង់តុង, មានពួកគណៈប្រតិភូនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង (ប្រធានាធិបតីង្វៀង-ហ៊ុយថូ), សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (នាយករដ្ឋមន្ត្រីផាំ-យ៉ាំងដុង), ណារ៉ូឡាវហាក់សាត (ទ្រង់សុផាណាវង្ស ) បានទទួលស្គាល់ជាផ្លូវការនិងជាឧឡារិក នៅចំពោះមុខរដ្ឋមន្ត្រីទី១ ជូអេនឡាយ (នៃសាធារណរដ្ឋប្រជាមានិតចិន) ការកំណត់ព្រំដែនកម្ពុជាឆ្នាំ១៩៦៣-១៩៦៩ និងបានសន្យាយ៉ាងហោចណាស់ជាឧឡារិក ក្នុងនាមប្រទេស ជាតិ និងប្រជារាស្ត្ររៀងៗខ្លួន គោរពជានិច្ច មានន័យថាជារៀងរហូតទៅ នូវគំនូសសីមាព្រំដែនរបស់យើង ។

( កកន ៖ សីហនុគឺជាសមាជិកនៃសន្និសិទកំពូលក្រុងកង់តុង ក្នុងវត្តមានដ៏ណាងគៀងគរប្រទេសកុម្មុយនិស្តទាំងបី ឲ្យមកជួយច្បាំងនៅក្នុងស្រុកខ្មែរ ដោយមានចិនជាមេខ្លោងនៅពីក្រោយ ។ បើពួកប្រទេសទាំងនោះបានសន្យាជាមួយសីហនុនៅមុខចិន គឺសីហនុត្រូវវិលត្រឡប់ទៅរកចិនវិញ ដើម្បីនិយាយប្រាប់ថា ពួកវាទាំងបីប្រទេសអត់បានធ្វើតាមកិច្ចសន្យារបស់ខ្លួនទេ ។ តែសីហនុអត់បានធ្វើរឿងហ្នឹងសោះ ព្រោះទីមួយរវល់សប្បាយដោយបានពួកខ្មែរក្រហមលើកឲ្យឡើងធ្វើជា<ប្រមុខរដ្ឋអស់មួយជីវិត> និងទី២ រវល់បានឡើងសោយរាជ្យជាថ្មី ។ យើងសំណូមពរថា បើសីហនុបានដឹងយ៉ាងច្បាស់ អំពីពួកប្រទេសទាំងបីមិនព្រមគោរពភាពត្រឹមត្រូវនិងភាពស្របច្បាប់នៃព្រំដែនខ្មែរយ៉ាងដូច្នេះទៅហើយ គាត់ត្រូវតែលុបចោលសន្ធិសញ្ញាខ្មែរ-យួនឆ្នាំ១៩៧៩-៨០-៨២-៨៣ និង៨៥ទៅ ដោយអនុលោមតាមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងយោងតាមមាត្រាទី៨នៃរដ្ឋធម្មនុញ្ញខ្មែរ ? ។ តើមកពីហេតុអ្វីបានជាគាត់មិនព្រមលុបចោល ? រឿងនេះងាយសោះទេតើ គឺគាត់ធ្វើតែខាងផ្នែកខ្មែរទៅបានហើយ ! ) ។

ទីពីរ, កម្ពុជានៃរាជាណាចក្រទី២របស់យើង (តំណាងដោយក្រុមឯ.ឧ. វ៉ា-គឹមហុង) កំពុងធ្វើអត្តឃាត ដោយទទួលស្គាល់នៅក្រោមភ្នែកច្បាប់អន្តរជាតិ ថាស្រុកខ្មែរពុំមានព្រំដែនពិតប្រាកដទេ ។

ការយល់ព្រមទទួលយកជាផ្លូវការនូវការចរចាគ្នាឡើងវិញអំពីបញ្ហាព្រំដែនរបស់យើង គឺហាក់ដូចជាស្រុកខ្មែរ «សម័យអង្គរថ្មី» នៃយើងទទួលស្គាល់ខ្លួនឯងថា ពុំដឹងព្រំដែនដីគោកនិងសមុទ្រនៅត្រង់កន្លែងណាទេ ។

នៅក្នុងប្រការនេះ, ការប្រើពាក្យ<អត្តឃាត> គឺពុំបានបំផ្លើសឡើយ ពីព្រោះស្រុកមួយដែលទទួលស្គាល់ថា ខ្លួនពុំមានព្រំដែនច្បាស់លាស់ និងស្របច្បាប់ គឺជាស្រុកស្លាប់ » ។

q q

q

«ព្រឹត្តិប័ត្រឯកសារប្រចាំខែ

«នរោត្តម-សីហនុ

«ប៉េកាំង, ថ្ងៃទី១៧ មីនា ២០០៥

«ប៉ុន្មានឆ្នាំកន្លងមកនេះ, ពួកខ្មែរកម្ពុជាក្រោម បាននិយាយយ៉ាងច្រើន និងសរសេរយ៉ាងច្រើនអំពី «ភាពមិនត្រឹមត្រូវនិងភាពមិនស្របច្បាប់ » ក្នុងការប្រគល់កម្ពុជាក្រោមទៅឲ្យវៀតណាមនៅក្នុងឆ្នាំ១៩៤៩ដោយបារាំង ។

ខ្ញុំក៏បានសរសេរយ៉ាងច្រើនផងដែរអំពីរឿងនេះ

ទោះបីដូច្នេះក៏ដោយ, ក្នុងថ្ងៃនេះ, ជាការសំខាន់ដែលត្រូវបញ្ជាក់ថា៖

១- កាលឆ្នាំ១៨៦០, ពេលកម្លាំងអាណានិគមបារាំងសំរេចយក(ដោយកម្លាំង)នូវកម្ពុជាក្រោម (ដែលគេហៅ<កូសាំងស៊ីន>តាមបារាំង) កងទ័ពខ្មែររបស់ព្រះបាទអង្គឌួង និងក្រោយមករបស់ព្រះបាទនរោត្តម បានធ្វើការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាជាមួយកងទ័ពជនជាតិអណ្ណាម ដែលស្ថិតនៅក្រោមអធិរាជអណ្ណាម ៖ គឺកងទ័ពខ្មែរបានការពារនគរ, ទឹកដីដ៏ជាទីសក្ការ:នៃកម្ពុជាក្រោមរបស់គេ ទោះបីកងទ័ពនៃអធិរាជអណ្ណាម ចង់ត្រួតត្រាកម្ពុជា និងបញ្ចូលទៅក្នុងទឹកដីរបស់គេ ដែលគេហៅថារាជាធិរាជាណាចក្រអណ្ណាមក៏ដោយ ។

( <u>កកន</u> ៖ ចុះចំណែកសីហនុ តើហេតុអ្វីបានជាគ្មានការតស៊ូអ្វីប្រឆាំងនឹងបារាំងយ៉ាងខ្លាំងក្លា ក្នុងការប្រគល់ទឹកដីនេះទៅយួនយ៉ាងដូច្នេះ ? យើងឃើញតែខាងខ្មែរបញ្ជូនគណ:ប្រតិភូរប៉េះរប៉ោះទៅស្រុកបារាំង រួចហើយត្រូវសីហនុសង្ស័យនឹងច្រណែនថា ជាពួកមនុស្សរបស់គណបក្សប្រជាធិបតេយ្យ បានបញ្ជាឲ្យវិលត្រឡប់មកស្រុកខ្មែរវិញ ដោយទុកចោលឲ្យអាំងដឺរី នូវកិច្ចការអាយុជីវិតដ៏ធំធេងរបស់ជាតិ ។ បើនិយាយថា សីហនុគាត់យកកម្ពុជាក្រោមទៅដូរគ្នានឹងព្រះរាជបល្ល័ង្គ ប្រហែលត្រឹមត្រូវជាង ។ ឯករាជភាពដែលបារាំងបោះឲ្យខ្មែរកាលពីឆ្នាំ១៩៥៣ មិនប្រាកដជាជ័យជំនះនៃព្រះរាជបូជនីយកិច្ចទេ គឺស្រុកខ្មែរបានឯករាជ្យតែឈ្មោះប៉ុណ្ណោះ ព្រោះយើងបានបាត់បង់<កម្ពុជាក្រោម>ទាំងមូលទៅយួន ) ។

q

២- បារាំង, ដោយសំរេចបានជោគជ័យក្នុងការធ្វើអាណានិគមកម្ពុជាក្រោម ដោយដាក់ជាអាណានិគមរបស់ខ្លួន និងធ្វើជាខេត្រខ័ណ្ឌនៃរដ្ឋរបស់ខ្លួន (ចក្រភពរបស់ខ្លួន) បានសំរេចជោគជ័យក្នុងការបញ្ចប់រហូតដល់ឆ្នាំ១៩៤៩ (ឆ្នាំដែលបារាំងទទួលស្គាល់សន្ធិសញ្ញាឯករាជ្យកម្ពុជានិងអណ្ណាមនៃអធិរាជបាវដាយ) នូវការប្រឈមមុខអាវុធគ្នារវាងកងទ័ពខ្មែរនិងអណ្ណាម, ដើម្បីដណ្តើមធ្វើជាម្ចាស់នៃដែនដីកម្ពុជាក្រោម ។ បារាំងដើរតួរនាទីជាចោរទី៣ លួចផ្លែ<ម៉ារុង> <កូសាំងស៊ីន> ដែលកំពុងតែអាំងនៅលើភ្លើង ។

q

៣- ជាមួយការលេចផុសឡើងនៃ «អ៊ុំហូ» (ហូ-ជីមិញ) ជាវិរបុរសជាតិនៃប្រជាជនវៀតណាម (ខាងជើង កណ្តាល និងខាងត្បូង) សាធារណរដ្ឋបារាំងគិតរារាំងហូ-ជីមិញនិងពួកវៀតមិញ កុំឲ្យដណ្តើមយកកូ-សាំងស៊ីន ។ បារាំងនេះគិតថា ដោយប្រគល់កូសាំងស៊ីនទៅឲ្យបាវដាយប្រជាពលរដ្ឋវៀតណាមខាងត្បូងមុខជាពេញចិត្តធ្វើជាអាយ៉ងនៃចក្រភពនេះពុំខាន ។ ប៉ុន្តែវាជាការគិតខុសដ៏អាក្រក់មួយ, ខ្វះការពិចារណានិងមិនយល់ដឹងអ្វីទាំងអស់ អំពីបញ្ហាជាគ្រឹះមូលដ្ឋានរបស់វៀតណាមនិងកម្ពុជា ។

<u>យោបល់របស់ខ្ញុំ</u> ៖ ចាប់ផ្តើមពីប្រវត្តិសាស្ត្រនិងការពិតដែលពុំអាចប្រកែកបាន នៅពេលដែលបារាំងចុះជាន់ដីកម្ពុជាក្រោមពេលណាមក, កម្ពុជាក្រោមនេះ ពុំមែនត្រួតត្រាដោយពួកអណ្ណាមប៉ុណ្ណោះទេ (ចាប់ពីចក្រភពអណ្ណាមមក), កម្ពុជារបស់យើង, ជាតិយើង និងប្រជារាស្ត្រខ្មែររបស់យើង មានសិទ្ធិនិងកាតព្វកិច្ចនឹងផ្តន្ទាទោស ទៅលើភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរនៃសាធារណរដ្ឋបារាំង ដែលនៅពេលគាត់ឈប់លែងធ្វើអាណានិគមត្រួតត្រាលើកម្ពុជាក្រោមហើយ គាត់ត្រូវប្រគល់ត្រឡប់មកប្រទេសកម្ពុជាយើងវិញ យ៉ាងហោចណាស់ចំនួន៥០%នៃកម្ពុជាក្រោមទាំងមូលបញ្ចូលមកក្នុងរាជាណាចក្រកម្ពុជា » ។

q q

q

«ព្រឹត្តិប័ត្រឯកសារប្រចាំខែ

«នរោត្តម-សីហនុ

«ប៉េកាំង, ថ្ងៃទី១៨ មីនា ២០០៥

(បកប្រែក្រៅផ្លូវការដោយគណ:កម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង)

«បាត់បង់ព្រំដែនដែលត្រឹមត្រូវតាមលក្ខណ:ច្បាប់ និងបាត់បង់បូរ-ណភាពទឹកដី គឺបាត់បង់នូវព្រលឹងរបស់ខ្លួន ក្នុងឋាន:ជាប្រទេស ក្នុងឋាន:ជារដ្ឋ ជាប្រជាជាតិ ជាប្រជារាស្ត្រ និងក្នុងឋាន:ជាជាតិសាសន៍ ។

ព្រំដែនរបស់យើងដែលត្រឹមត្រូវទៅតាមច្បាប់នេះ មានចែងនិងគូសយ៉ាងច្បាស់ នៅលើផែនទីដែលបានរៀបចំឡើងនិងបោះពុម្ពផ្សាយដោយសហរដ្ឋអាមេរិក ដើម្បីបំរើការត្រូវការរបស់គេនៅក្នុងសង្គ្រាមមួ-យនិងប្រទេសវៀតណាម នៅក្នុងទសវត្ស១៩៦០និង១៩៧០ ។ ខ្ញុំគិតជាពិសេសទៅដល់ផែនទីអគ្គសេនាធិការ ដែលនៅលើនោះមានគូសយ៉ាងច្បាស់លាស់ នៅក្នុងមាត្រដ្ឋានយ៉ាងធំគ្រប់គ្រាន់ នូវព្រំប្រទល់រវាងប្រ-ទេសថៃឡង់ ប្រទេសកម្ពុជា ប្រទេសវៀតណាម និងប្រទេសឡាវ ។ នៅលើផែនទីអគ្គសេនាធិការរបស់សហរដ្ឋអាមេរិកនោះ (ដែលធ្វើឡើងមិនមែនសំរាប់«ផ្គាប់ចិត្ត» ដល់ប្រទេសកម្ពុជានៃ«នរោត្តម-សីហនុ»ទេ) មានចុះរហូតដល់ភូមិខ្ទាតដែលតូចតាច ទាំងកូនព្រែកតូចៗ បឹងបួរ អ-ណ្តូង ឬក៏កន្លែងដែលមានទឹក ទាំងផ្លូវលំ ផ្លូវថ្មើរជើង ទាំងកូនភ្នំ ទាំងដំបូកអ្វីទាំងអស់ ដោយហេតុថាកងទ័ពអាមេរិកាំងនិងផ្កាយរណបដែលគេប្រើក្នុងកិច្ចប្រតិបត្តិការនានានោះត្រូវការចំណុចដែលល្អិតល្អន់ទាំងនេះ។

q

ដូចនេះបញ្ហាពុំមែនស្ថិតនៅលើការគូសបន្ទាត់ព្រំដែនថ្មីមួយទៀតរវាងប្រទេសថៃឡង់ វៀតណាម ឡាវ និងកម្ពុជានោះទេ ប៉ុន្តែ (ជាការមួយដែលស្របទៅតាមច្បាប់អន្តរជាតិ និងនៅក្នុងទំនៀមទំលាប់ទំនាក់ទំ-នងគ្នាល្អរវាងប្រទេសនានា) គឺការសុំឲ្យប្រទេសជិតខាងយើងទាំង៣ (ប្រទេសថៃឡង់ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតុប្រជាធិបតេយ្យឡាវ) គោរពនៅក្នុងទង្វើ «នៅលើដី» «on the ground», «sur le terrain même» នូវគំនូសព្រំដែនក្នុងដែនដីគោកនិងក្នុងដែនសមុទ្រ ដែលមានរវាងប្រទេសថៃឡង់និងកម្ពុជា រវាងប្រទេសវៀតណាមនិងប្រទេសកម្ពុជា និងរវាងប្រទេសឡាវនឹងប្រទេសកម្ពុជា ។ គំនូសព្រំដែននោះ ជាគំនូសដែលមានតាំងពីឆ្នាំ១៩៦៣រហូតមកដល់១៩៦៩មក ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់ នៅក្នុងផែនទីអគ្គ-សេនាធិការសហរដ្ឋអាមេរិក (ដែលមិនចូលចិត្តនឹងសីហនុទេ) នៅក្នុងទសវត្ស១៩៦០-១៩៧០ ។

q

តើនរណាខាងខ្មែរដែលត្រូវតែងតាំងផ្លូវការដោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាទី២ ដើម្បីនឹងទៅពិនិត្យឲ្យដល់ទីកន្លែងនៅលើគំនូសព្រំដែននេះ មួយគីឡូម៉ែត្រទៅមួយគីឡូម៉ែត្រ កន្លែងណាខ្លះដែលនៅដដែល និងកន្លែងណាដែលបានផ្លាស់ប្តូរ (ត្រង់នេះយើងជាខ្មែរ យើងមិនយល់ព្រមទទួលឡើយ) នៅតាមកន្លែងនីមួយៗ ? ដោយមិនគិតពីបុគ្គលិក

រដ្ឋបាល ប៉ូលិស និងកងទ័ពដែលត្រូវមានចំនួនច្រើននោះ និងនិយាយតែនៅលើ «អ្នកដឹកនាំ» ដែលត្រូវនៅធ្វើការនិងបោះជំរំនៅផ្ទាល់ដល់ទីកន្លែង យើងត្រូវតែងតាំងដោយព្រះរាជក្រឹត្យនូវអ្នកដឹកនាំដូចមានខាងក្រោមនេះ ៖ តំណាងគណបក្សប្រជាជនម្នាក់ តំណាងគណបក្សហ៊្វុនស៊ិនប៉ិចម្នាក់ តំណាងគណបក្សសម-រង្ស៊ីម្នាក់ និងបើអាចធ្វើបាន លោកស៊ាន-ប៉េងសែ (ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ជាអ្នកលន់-នល់និយម-សាធារណរដ្ឋខ្មែរ ពុំមែនជាអ្នកសីហនុនិយមទេ) ។

ๆ

ជាការមួយដែលគួរជឿបាន ប្រទេសជិតខាងយើងទាំង៣ នឹងច្រានចោលនូវមធ្យោបាយនេះ ដែលជាដំណោះស្រាយមួយទៅនឹងបញ្ហាព្រំដែន ដែលមិនត្រូវមានទាល់តែសោះនេះ ។ ប្រសិនបើបទេសទាំងនេះច្រានចោល នេះបង្ហាញឲ្យឃើញថា ប្រទេសទាំងនេះមានបំណងដោយពិតប្រាកដក្នុងការសម្លាប់ប្រទេសកម្ពុជាយើង ហើយដែលគេនឹងធ្វើឲ្យរលាយទៅនៅក្នុងអនាគតមិនជាយូរប៉ុន្មានខាងមុខនេះ » ។

( <u>កកន</u> ៖ បើយោងតាមអត្ថបទខាងលើនេះ សីហនុបានដឹងរួចស្រេចទៅហើយថា ពួកប្រទេសជិតខាងទាំង៣នោះ គេមុខជាច្រានចោលផែនការត្រួតពិនិត្យមើលព្រំដែននេះដាច់ខាត ។ ហើយសីហនុក៏បានបញ្ជាក់យ៉ាងច្បាស់ថា «ប្រទេសទាំង៣នេះមានបំណងយ៉ាងពិតប្រាកដ ក្នុងការសម្លាប់ប្រទេសកម្ពុជាយើង» (sic) ។ បើអញ្ចឹងទេ តើហេតុអ្វីបានជាសីហនុទ្រាំនៅស្ងៀមទៅកើត ? ។ ប្រការសន្ធិសិទក្រុងកង់តុង និងកិច្ចស-ន្យាមួយចំភ្លូសរបស់ពួកយួនយៀកកុង... ចាត់ទុកថាភ្លើឬស៊ីជោរ «ចា-ញ់បោកគេ» រហូតស្ទើររលាយនគរទៅចុះ ។ យើងសូមឆ្ងល់ថា ៖ ចុះហេតុអ្វីបានស្តេចឪសីហនុនិងស្តេចកូននរោត្តម-សីហមុនី មិនព្រមធ្វើនូវរឿងដែលខ្លួនអាចធ្វើបាន ? ។ រឿងនេះគឺ ការធ្វើសេចក្តីប្រកាសលុបចោល «សន្ធិសញ្ញាខ្មែរ-យួនឆ្នាំ១៩៧៩-៨០-៨២-៨៣ និង៨៥» ? ។ យើងចង់ឃើញត្រឹមតែបន្តិចប៉ុណ្ណឹងសិនទេ កិច្ចការផ្សេងៗទៀត ដូចជាការដាក់ពាក្យបណ្តឹងទៅតុលាការអន្តរជាតិជាដើម វាជាជំហានទី២ ដែលខ្មែរត្រូវធ្វើតទៅមុខទៀត ។ បើសីហនុហើយនិងកូនមិនព្រមចាប់ផ្តើមធ្វើត្រឹមតែបន្តិចនេះផង តើសង្ឃឹមអ្វីនឹងធ្វើដល់ទៅប្រការធំៗនោះ ? ។ ដូចយើងបាននិយាយរួចមកហើយដូច្នោះ បើកាលណាមានបញ្ហាអ្វីរំពើករំ-ពើងកើតឡើង ទាក់ទងទៅនឹងបញ្ហាព្រំដែនឬបញ្ហាបាត់បង់ទឹកដីខ្មែរ សីហនុគាត់គ្រាន់តែធ្វើជា «ហេកហាក» ដើម្បីឲ្យផុតពីមុខពីមាត់គាត់ទៅប៉ុ-ណ្ណោះ ។ អ្នកដែលអាចសេចក្តីប្រកាសលុបចោលសន្ធិសញ្ញាមានតែពីរនាក់គត់ទេគឺ ៖ ព្រះមហាក្សត្រ និងនាយករដ្ឋមន្ត្រី តែជាតំណាងឯករា-ជភាព, អធិបតេយ្យភាព និងបូរណភាពទឹកដីខ្មែរ ។ គណៈកម្មាធិការព្រំដែនកម្ពុជារបស់លោកស៊ាន-ប៉េងសែ ពុំមានលក្ខណៈតាមផ្លូវច្បាប់អាចធ្វើបានទេ ក្រៅតែអំពីខំប្រឹងខ្លះខ្លែងជួយជំរុញឲ្យបញ្ហានេះកើតឡើង និងបានសំរេចជោគជ័យជាស្ថាពរ ។ យើងសូមគូសបញ្ជាក់ថា «បញ្ហាព្រំដែន» ពុំមែនជាបញ្ហារបស់អ្នកណាម្នាក់ទេ តែគឺជាបញ្ហារបស់ប្រជាជាតិខ្មែរទាំងមូល (ស្តេច ពួកមន្ត្រី និងប្រជាពលរដ្ឋ) ។ ការបែងចែកខ្មែរជា កុម្មុយនិស្តនិយម, រាជានិយម (សីហនុនិយម) និងសាធារណរដ្ឋនិយម វាំពុំត្រូវឲ្យកើតមានឡើយ ។ ក្រាំងសារតាជាតិបានកត់ត្រារួចទៅហើយ ថាអ្នកណាដែលជាមេខ្លោង វង្វេង ស៊ីជោរ ចាញ់បោកខ្លាំង ធ្វើឲ្យទឹកដីនិងអាយុជីវិតខ្មែរត្រូវខាតវិចវិលនិងបាត់បង់ ។ យើងបានជឿជាក់ថា គឺមេខ្លោង«ឃាតកសម្លាប់ជាតិខ្លួន»នេះឯងហើយ ដែលកំពុងជួយសត្រូវជិតខាង ឲ្យបន្តបំផ្លាញកម្ពុជា ។៚